# សេចក្តីណែនាំអំពីប្រាក់កម្ចីលើធានារ៉ាប់រងនៃការចាកចេញរបស់ពលករបរទេស

## ☐ គោលដៅប្រាក់កម្ចី

○ 'ចំពោះពលករបរទេស (E-9, H-2) ដែលមិនអាចចាកចេញដំណើរ ដោយសារតែមិនមានជើងយន្តហោះដែលបណ្តាលមកពីជំងឺកូវីដ១៩ ហើយបានផុតរយៈពេល កំណត់ការងារក្រោយថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២០។

* គោលដៅពីមុនៗ សម្រាប់ធានារ៉ាប់រងនៃការចាកចេញដំណើររបស់ពលករបរទេស ដែលត្រូវការពេលវេលាសម្រាកព្យាបាលជំងឺលើសពី៤សប្តាហ៍ ហើយការរងរបួសនោះ គឺបណ្តាលមកពីការផ្លាស់ប្តូរកន្លែងការងារឬកិច្ចសន្យារបស់ពលករពលការនីត្រូវបានផុតកំណត់ដោយសារម្ចាស់អាជីវកម្មរបស់ពួកគេបានបិទ។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌប្រាក់កម្ចីក៏ត្រូវបានបន្ធូរបន្ថយជូន។

* មូលដ្ឋានពាក់ព័ន្ធ : 1. ប្រាក់កម្ចីស្តីពីធានារ៉ាបរងនៃការចាកចេញដំណើរនិងធ្វើឱ្យវាមានដំណើរការបាន តាមរយៈ (ក្រសួងការងារ)

2. ប្រាក់កម្ចីស្តីពីធានារ៉ាបរងនៃការចាកចេញដំណើរសម្រាប់ពលករបរទេសដើម្បីការ ពារជីវភាពរស់នៅរបស់ពួកគេ។

## ☐ រយៈពេលដាក់ពាក្យស្នើសុំប្រាក់កម្ចី

○ ចាប់ពីថ្ងៃបញ្ចប់នៃរយៈពេលការងាររហូតដល់ថ្ងៃមុនពេលចេញដំណើរ

* ក្នុងករណីពលករបរទេសដែលផ្លាស់ប្តូរកន្លែងធ្វើការ គឺដូចពីមុនក្នុងរយៈពេល ៨ខែបន្ទាប់ពីការផ្លាស់ ប្តូរកន្លែងការងារ។

## ☐ ចំនួនទឹកប្រាក់កម្ចី : អាចខ្ចីបាន៥០% នៃប្រាក់ធានារ៉ាប់រងនៃការចាកចេញដំណើរ

## ☐ ការប្រាក់កម្ចី : អាត្រាការប្រាក់ប្រចាំឆ្នាំ3%

* អត្រាការប្រាក់ពិតប្រាកដគឺ ១,៥% ជាប្រចាំឆ្នាំ ពីព្រោះធានារ៉ាប់រងនៃការចាកចេញដំណើរគឺ ផ្តល់១,៥% នូវការប្រាក់ប្រចាំឆ្នាំរហូតដល់ពេលចាកចេញដំណើរ។

## ☐ ការសងប្រាក់កម្ចី

○ អ្នកអាចធ្វើការបង់សងជូនវិញពេលណាក៏បាន មិនមានការកាត់ថ្លៃនោះទេ ប្រសិនបើ បានបង់មុនជូនវិញទាំងអស់។

○ ប្រសិនបើមិនត្រូវបានបង់សងរហូតដល់ចប់រយៈពេលនៃប្រាក់កម្ចីនោះទេ ប្រាក់កម្ចីនោះនឹងត្រូវបានកាត់ដោយស្វ័យប្រវត្តិពីធានារ៉ាប់រងនៃការចាកចេញដំណើរនៅពេលដែលចាកចេញដំណើរ។

## ☐ ឯកសារសម្រាប់ប្រាក់កម្ចី

○ លិខិតអនុញ្ញាតឱ្យពន្យាពេលចាកចេញដំណើរ (ចេញដោយក្រសួងយុត្តិធម៌)

○ ពាក្យស្នើសុំប្រាក់កម្ចី (ក្រុមហ៊ុនធានារ៉ាប់រងសាំសុងហ្វាជេរ)

○ សៀវភៅធនាគារ

○ លិខិតឆ្លងដែន(ឬអត្តសញ្ញាណបណ្ណសម្គាល់ខ្លួនជនបរទេស)

☐សម្រាប់ពាក្យស្នើសុំប្រាក់កម្ចីនិងការសាកសួរព័ត៌មានផ្សេងៗសូមទាក់ទងមកកាន់ក្រុមហ៊ុនធានារ៉ាប់រងសាំសុងហ្វាជេរតាមរយៈទូរស័ព្ទលេខ:(☎1600-0266)